## ស្ថានភាពអតិផរណានៅខែមីនា ឆ្នាំ២០១៧

### ក/ អតិផរណាក្នុងប្រទេស

សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅភ្នំពេញក្នុងខែមីនា ឆ្នាំ២០១៧ ពុំមានការកើនឡើងទេធៀបនឹងខែមុន។ សន្ទស្សន៍ថ្លៃនៃក្រុមទំនិញមួយចំនួនបានកើនឡើងបន្តិច ដូចជាសន្ទស្សន៍ថ្លៃភេសជ្ជៈដែលមានជាតិស្រវឹងនិងថ្នាំជក់, សន្ទស្សន៍ថ្លៃអាហារនិងភេសជ្ជៈមិនមានជាតិស្រវឹងបានស្ថិតនៅថេរ ក្នុងនោះថ្លៃទំនិញមួយចំនួនមានការកើនឡើងដូចជាសាច់ជ្រូក សាច់ទានិងផ្លែឈើ ប៉ុន្តែត្រូវបានផាត់ទាត់ដោយការថយចុះថ្លៃទំនិញមួយចំនួនទៀតដូចជាសាច់មាន់ ត្រីស្រស់និងបន្លែ។

បើធៀបនឹង១ឆ្នាំមុន អតិផរណាមានអត្រា ៤,២% ក្នុងនោះសន្ទស្សន៍ថ្លៃអាហារនិងភេសជ្ជៈគ្មានជាតិស្រវឹងបានកើនឡើង ៥,៦% ដោយសារកំណើនថ្លៃសាច់គោ សាច់មាន់ សាច់ជ្រូក ត្រីស្រស់និងបន្លែ។ សន្ទស្សន៍ថ្លៃការដឹកជញ្ជូនបានកើនឡើង ៦% ក្នុងនោះថ្លៃប្រេងសាំងធម្មតាកើន ១៥,៤% និងថ្លៃប្រេងម៉ាស៊ូតកើន ១២,៥%។ ក្នុងរយៈពេលបីខែដើមឆ្នាំ២០១៧ ថ្លៃប្រេងសាំងនិងប្រេងម៉ាស៊ូតជារួមខ្ពស់ជាងក្នុងរយៈពេលដូចគ្នាឆ្នាំ២០១៦ ដែលកំណើននេះគឺស្របនឹងនិន្នាការថ្លៃប្រេងឆៅលើទីផ្សារអន្តរជាតិផងដែរដោយសារការចាប់ផ្តើមអនុវត្តកិច្ចព្រមព្រៀងកាត់បន្ថយបរិមាណផលិតប្រេងនៃបណ្តាប្រទេសសមាជិកOPEC និងប្រទេសផលិតប្រេងមួយចំនួនទៀតផងដែរ។ ទន្ទឹមនឹងកំណើនអតិផរណា ជាពិសេសលើថ្លៃម្ហូបអាហារកសិផលមួយចំនួនដែលលក់ចេញពីកសិដ្ឋានបានថយចុះ ដូចជាថ្លៃស្រូវ ដំឡូងមីនិងម្រេចជាដើម។

| តារាង១÷ បម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញទាំង១២ក្រុម ក្នុងខែមីនា ឆ្នាំ២០១៧ | | |
|---|---|---|
| | ធៀបនឹងខែមុន | ធៀបនឹង១ឆ្នាំមុន |
| **មុខទំនិញគ្រប់មុខ** | **0.0** | **4.3** |
| ១-អាហារនិងភេសជ្ជៈមិនមានជាតិស្រវឹង | 0.0 | 5.6 |
| ២-ភេសជ្ជៈមានជាតិស្រវឹងនិងថ្នាំជក់ | 1.1 | 3.9 |
| ៣-សម្លៀកបំពាក់និងស្បែកជើង | 0.1 | 3.6 |
| ៤-ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈដទៃទៀត | 0.2 | 0.7 |
| ៥-គ្រឿងសង្ហារឹម សម្ភារៈប្រើប្រាស់ និងការថែទាំ | -0.2 | 0.8 |
| ៦-សុខាភិបាល | 0.3 | 2.2 |
| ៧-ការដឹកជញ្ជូន | 0.1 | 6.0 |
| ៨-គមនាគមន៍ | 0.2 | -0.1 |
| ៩-ការកំសាន្ត និងវប្បធម៌ | 0.6 | 2.6 |
| ១០-ការសិក្សា | 0.0 | 0.0 |
| ១១-ភោជនីយដ្ឋាន | -0.3 | 3.6 |
| ១២-ទំនិញ និងសេវាកម្មផ្សេងៗ | -0.5 | 1.8 |

| តារាង២÷ បម្រែបម្រួលសន្ទស្សន៍ថ្លៃម្ហូបអាហារសំខាន់ៗ (%) | | | | | | |
|---|---|---|---|---|---|---|
| មុខទំនិញ | ធៀបនឹងខែមុន | | | ធៀបនឹង១ឆ្នាំមុន | | |
| | ២០១៧ | | | ២០១៧ | | |
| | មករា | កុម្ភៈ | មីនា | មករា | កុម្ភៈ | មីនា |
| អង្ករ | -0.5 | 0.3 | 0.1 | 2.6 | 2.9 | 3.2 |
| សាច់គោ | 0.3 | 0.0 | 0.0 | 6.1 | 4.4 | 4.0 |
| សាច់មាន់ | 0.9 | -0.4 | -0.9 | 8.4 | 6.0 | 4.5 |
| សាច់ទា | 0.1 | -0.7 | 0.2 | 1.7 | 0.7 | 1.8 |
| សាច់ជ្រូក | 0.5 | -0.2 | 0.1 | 4.6 | 3.2 | 3.5 |
| ត្រីទឹកសាប និង ត្រីទឹកសមុទ្រ | 0.0 | 0.5 | -0.2 | 9.6 | 10.0 | 9.0 |
| ក្នុងនោះត្រីស្រស់ | 0.2 | 0.5 | -0.1 | 10.1 | 10.7 | 10.1 |
| ផ្លែឈើ | 0.6 | -0.1 | 0.5 | 6.2 | 3.9 | 5.2 |
| ផ្លែឈើស្រស់ | 0.6 | 0.0 | 0.5 | 6.4 | 4.2 | 6.0 |
| បន្លែ | 0.3 | -0.6 | -0.9 | 15.7 | 13.2 | 11.8 |
| បន្លែជាស្លឹក | -0.2 | -0.8 | -1.7 | 16.6 | 14.3 | 10.1 |
| បន្លែជាផ្លែ | 1.2 | -1.6 | -0.9 | 26.1 | 20.7 | 21.7 |

## ខ/ អតិផរណាប្រចាំឆ្នាំរបស់ប្រទេសមួយចំនួន

| តារាង៣÷ អតិផរណាប្រចាំឆ្នាំក្នុងប្រទេសមួយចំនួន (%) | | | | | | |
|---|---|---|---|---|---|---|
| ប្រទេស | ២០១៦ | | | ២០១៧ | | |
| | មករា | កុម្ភៈ | មីនា | មករា | កុម្ភៈ | មីនា |
| ប្រទេសកម្ពុជា | 3.0 | 2.3 | 2.0 | 4.4 | 4.0 | 4.3 |
| ប្រទេសវៀតណាម | 0.8 | 1.3 | 1.69 | 5.2 | 5.0 | 4.7 |
| ប្រទេសថៃ | -0.5 | -0.5 | -0.5 | 1.6 | 1.4 | 0.8 |
| ប្រទេសម៉ាឡេស៊ី | 3.5 | 4.2 | 2.6 | 3.2 | 4.5 | 5.1 |
| ប្រទេសឥណ្ឌូនេស៊ី | 4.1 | 4.4 | 4.5 | 3.5 | 3.8 | 3.6 |
| ប្រទេសហ្វីលីពីន | 1.4 | 0.9 | 1.1 | 2.7 | 3.3 | 3.4 |
| ប្រទេសចិន | 1.8 | 2.3 | 2.3 | 2.5 | 0.8 | 0.9 |
| ប្រទេសកូរ៉េខាងត្បូង | 0.8 | 1.2 | 1.0 | 2.0 | 1.9 | 2.2 |
| ប្រទេសជប៉ុន | -0.1 | 0.3 | 0.0 | 0.4 | 0.3 | 0.2 |
| ប្រភពទិន្នន័យ<br>(១) ប្រទេសកម្ពុជា គឺពីវិទ្យាស្ថានជាតិស្ថិតិ(NIS)<br>(២) ប្រទេសផ្សេងៗទៀត ពីគេហទំព័រ http://www.tradingeconomics.com; | | | | | | |

**<u>កំណត់សម្គាល់</u>**

ការចងក្រងសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (CPI) នៅភ្នំពេញ÷

- ថ្លៃទំនិញដែលត្រូវបានជ្រើសរើសមានចំនួន ២៥៩មុខ
- ថ្លៃមុខទំនិញភាគច្រើនត្រូវបានប្រតិបត្តិការប្រមូលពីផ្សារចំនួន ៥
- ជាទូទៅថ្លៃត្រូវបានប្រមូលពីតូបគំរូចំនួន ៤ក្នុងផ្សារនីមួយៗ
- សម្រាប់មុខទំនិញដែលមិនដាក់លក់នៅទីផ្សារ ថ្លៃត្រូវបានប្រមូលពីតូបនៅជិតៗផ្សារ
- សន្ទស្សន៍ថ្លៃនៃមុខទំនិញត្រូវបានចងក្រងតាមមធ្យមរេខាគណិតសាស្ត្រ (geometric average)

ប្រភព÷ ក្រសួងផែនការ (វិទ្យាស្ថានជាតិស្ថិតិ)

***រៀបចំនិងធ្វើចំណោលដោយ***

***នាយដ្ឋានស្ថិតិ***

***អគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ***

***ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ***